ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង កិច្ចការនារី

លេខ.....០៩៥.........កកន/ប្រក

# ប្រកាស

## ស្ដីពីការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី ខេត្ត-ក្រុង

***

## រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ០៦ /នស /៩៤ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស /រកម/ ០១០៥./០០២ ចុះថ្ងៃទី១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- យោងតាមតំរូវការចាំបាច់

## សម្រេច

ប្រការ១: ត្រូវបានបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីខ្នាតធំ ខ្នាតមធ្យម ខ្នាតតូច ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង និងមន្ទីរកិច្ចការនារី ខេត្ត -ក្រុង មានដូចខាងក្រោម :

**ក.មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីខ្នាតធំ មាន :**

១-មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីខេត្តកំពត មានទីតាំងនៅក្នុងភូមិត្រពាំងធំ ឃុំជុំគ្រៀល ស្រុកកំពត ខេត្តកំពត ។

២-មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីព្រះអង្គម្ចាស់ក្សត្រី នរោត្តមម៉ារីរណឫទ្ធិ ខេត្តកំពង់ឆ្នាំង មានទីតាំងនៅក្នុងភូមិអូរសណ្ដាន់ ឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

៣-មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី សម្តេចព្រះមហាក្សត្រីយានីព្រះកុសមៈខេត្តកំពង់ចាម មានទីតាំងនៅក្នុងភូមិត្រពាំងជ្រៃ ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

៤-មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីក្រុងប៉ៃលិន មានទីតាំងនៅក្នុងភូមិក្បាលប្រលាន សង្កាត់អូរតាវៅ ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន។

៥-មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីខេត្តសៀមរាប មានទីតាំងនៅក្នុងភូមិភ្នំ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។

៦-មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី សម្តេចម៉ែខេត្តកំពង់ស្ពឺ មានទីតាំងនៅភូមិចំបក់ ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

៧-មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីក្រុងកែប មានទីតាំងនៅក្នុងភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ខណ្ឌកែប ក្រុងកែប។

៨-មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីក្រុងព្រះសីហនុ មានទីតាំងនៅក្នុងមណ្ឌលទី១ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីខ្នាតធំដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។ ប្រធានមានឋានៈស្មើអនុប្រធានមន្ទីរកិច្ចការនារីខេត្ត-ក្រុង និងអនុប្រធានមានឋានៈស្មើប្រធានការិយាល័យ នៃមន្ទីរកិច្ចការនារីខេត្ត-ក្រុង។

**ខ.មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីខ្នាតមធ្យម មាន :**

១-មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីខេត្តឧត្តរមានជ័យ មានទីតាំងនៅក្នុងឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ ។

២-មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីខេត្តបន្ទាយមានជ័យ មានទីតាំងនៅភូមិគោរដ្ឋាន ឃុំអូរអំបិល ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីខ្នាតមធ្យមដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។ ប្រធានមានឋានៈស្មើប្រធានការិយាល័យនៃមន្ទីរកិច្ចការនារីខេត្ត-ក្រុង និងអនុប្រធានមានឋានៈស្មើអនុប្រធានការិយាល័យ នៃមន្ទីរកិច្ចការនារីខេត្ត-ក្រុង។

**គ.មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីខ្នាតតូច** រួមមានមជ្ឈមណ្ឌលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង និងមន្ទីរកិច្ចការនារីខេត្ត-ក្រុងដែលគ្មានចែងក្នុងចំនុចកនិងខខាងលើ។

មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីខ្នាតតូចដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។ ប្រធានមានឋានៈស្មើប្រធានការិយាល័យកិច្ចការនារីស្រុក-ខណ្ឌ និងអនុប្រធានមានឋានៈស្មើអនុប្រធានការិយាល័យ កិច្ចការនារីស្រុក-ខណ្ឌ។

**ប្រការ៦:** ការគ្រប់គ្រងមជ្ឈមណ្ឌលអភិវឌ្ឍស្ត្រីរួមមាន :

-អគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ គ្រប់គ្រង ត្រួតពិនិត្យ :

- ផ្នែកក្របខណ្ឌ មន្ត្រី បុគ្គលិក សិក្ខាកាម
- របាយការណ៍សកម្មភាព បញ្ជីសារពើភ័ណ្ឌ បញ្ជីការគណនេយ្យ ស្វែងរកមូលនិធិតាមគ្រប់រូបភាព និងបើកផ្ដល់ថវិកាសំរាប់មជ្ឈមណ្ឌល

-អគ្គនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍន៍សេដ្ឋកិច្ច និងអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ទទួលខុសត្រូវផ្ដល់សេវាបច្ចេកទេស ជំនាញវិជ្ជាជីវៈ និងសេវាសង្គមដល់មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី

-មន្ទីរកិច្ចការនារី ខេត្ត-ក្រុង គ្រប់គ្រង ត្រួតពិនិត្យបៀវត្ស ក្របខ័ណ្ឌ និងកិច្ចដំណើរការមជ្ឈមណ្ឌល ធានានិរន្តភាពការងាររបស់មជ្ឈមណ្ឌល ដោយប្រើប្រាស់ក្របខណ្ឌដែលមានស្រាប់ ។

**ប្រការ៧:** មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី មានតួនាទី និងភារកិច្ចដូចតទៅ :

១- អនុវត្តផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំនារីរតនៈ នៃក្រសួងកិច្ចការនារី

២- រៀបចំផែនការសកម្មភាពសំរាប់អភិវឌ្ឍមជ្ឈមណ្ឌល ដោយធ្វើការវិភាគអំពីតំរូវការចាំបាច់របស់ស្ត្រីនៅក្នុងខេត្ត-ក្រុង ស្រុកខណ្ឌ

៣- រៀបចំកម្មវិធីអភិវឌ្ឍន៍ជំនាញ មុខរបរស្របទៅតាមតំរូវការទីផ្សារនៅក្នុងតំបន់

៤- ផ្ដល់សេវាដើម្បីពង្រឹងភាពអង់អាចរបស់ស្ត្រីនៅលើផ្នែកសង្គម ច្បាប់ និងវប្បធម៌ ផ្ដល់សេវាព័ត៌មានទីផ្សារការងារជូនស្ត្រី ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ

៥- ផ្ដល់សេវាព័ត៌មាននៅលើឥណទាន ជូនទៅស្ត្រីដោយសហការជាមួយសហគ្រាសមីក្រូហិរញ្ញវត្ថុ

៦- តាមដាន និងវាយតំលៃអំពីសកម្មភាពរបស់សិក្ខាកាម ដើម្បីរៀបចំអនុសាសន៍ សំរាប់កែច្នៃផែនការមេ និងលំអិត

៧- ការងារផ្ទៃក្នុង :

- ពង្រឹងសមត្ថភាពបុគ្គលិកមជ្ឈមណ្ឌលផ្នែកអភិបាលកិច្ច និងផ្នែកទទួលខុសត្រូវលើការងារគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ
- ស្វែងរកថវិកា អាហារូបករណ៍ និងមូលនិធិទ្រទ្រង់កម្មវិធីអភិវឌ្ឍន៍ដល់នារីតាមរយៈអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងម្ចាស់ជំនួយនានា ដោយមានការឯកភាពពីក្រសួងកិច្ចការនារី

៨-គ្រប់គ្រង ទទួលខុសត្រូវ និងធ្វើរបាយការណ៍ចំណូលចំណាយថវិការដ្ឋ មូលនិធិជំនួយ និងធ្វើបញ្ជីសារពើភណ្ឌ ទ្រព្យសម្បត្តិរដ្ឋ និងជំនួយ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ មកមន្ទីរ និងក្រសួង

៩- បូកសរុបសកម្មភាពការងារដែលបានអនុវត្តកន្លងមក ព្រមទាំងរៀបចំទិសដៅសំរាប់កម្មវិធីថ្មី ហើយរាយការណ៍ជូនមន្ទីរកិច្ចការនារី ខេត្ត-ក្រុង និងក្រសួង ។

IKP ១៧ Aw

**ប្រការ៤:** ប្រកាសលេខ ០៩៣ កកនអ/ប្រក ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ របស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងរាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** គ្រប់អគ្គនាយក នៃអគ្គនាយកដ្ឋាន គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ គ្រប់ប្រធានមន្ទីរកិច្ចការនារី ខេត្ត-ក្រុង និងគ្រប់ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី ដូចក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ១៩

រាជធានីភ្នំពេញ.ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៧

រដ្ឋមន្ត្រី

ខ្ទឹង កន្ថាដារី

ចំលងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ